ធ៥-០៣-០១៦ ស.ជ.ណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្ទេរទៅ-មក ខេត្ត-ក្រុង និងការកំណត់កំរៃសេវា

ធនាគារជាតិនៃកម្ពុជា មានកិត្តិយសសូមជំរាបជូនដំណឹងដល់អតិថិជនដែលមានបើកគណនីនៅស្នាក់ការកណ្តាលធនាគារជាតិនៃកម្ពុជា និងតាមសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងជ្រាបថា ធនាគារជាតិនៃកម្ពុជាផ្តល់សេវាផ្ទេរប្រាក់ទៅ-មកខេត្តក្រុង តាមរយៈនាយកដ្ឋានប្រតិបត្តិការ និងសាខាធនាគារជាតិនៃកម្ពុជាខេត្ត-ក្រុងចាប់ពីពេលជូនដំណឹងនេះតទៅ។

## I. **អតិថិជនដែលទទួលបាននូវការផ្តល់សេវា**

១- <u>ផ្ទេរប្រាក់ពីធនាគារជាតិនៃកម្ពុជាទៅសាខាធនាគារជាតិខេត្ត-ក្រុង:</u>

- ក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានបើកគណនីនៅនាយកដ្ឋាន ប្រតិបត្តិការ

២- <u>ផ្ទេរប្រាក់ពីសាខាធនាគារខេត្ត-ក្រុងមកធនាគារជាតិនៃកម្ពុជា</u>

- រតនាគារខេត្ត-ក្រុង
- មន្ទីរស្ថាប័នខេត្ត-ក្រុងកំពង់ផែ អគ្គិសនី រដ្ឋាករទឹក
- សាខាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- អង្គការក្រៅរដ្ឋាភិបាល អង្គការសង្គម
- អាជីវករប្តូរប្រាក់ និង លោហធាតុមានតម្លៃដែលមានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា

## II. **បែបបទផ្ទេរប្រាក់**

អតិថិជនត្រូវបំពេញនូវបញ្ជាផ្ទេរប្រាក់តាមគំរូលេខ ១១ ចំពោះអតិថិជនជានីតិបុគ្គល ឬតាមគំរូលេខ ១២ ចំពោះ អតិថិជនជាឯកត្តជន ដោយភ្ជាប់ជាមួយនូវមូលប្បទានប័ត្រដកប្រាក់ពីគណនីរបស់ខ្លួន។ (សូមភ្ជាប់ជាមួយនេះនូវគំរូលេខ ១១ និងគំរូលេខ ១២)

## III. **កំរៃសេវា**

- កំរៃសេវាត្រូវគិតលើចំនួនប្រាក់ផ្ទេរ 0.10% (ជាប្រាក់រៀល ឬប្រាក់ដុល្លាររអាមេរិក)
- កំរិតអប្បបរមា ១២.០០០រៀល ឬ ៣ ដុល្លារ ក្នុងប្រតិបត្តិការផ្ទេរប្រាក់១លើក ការផ្ទេរប្រាក់ដែលជាថវិការដ្ឋមិនគិតកំរៃសេវាទេ។

កំរៃសេវាត្រូវបានគិតយកពីអតិថិជននៅធនាគារផ្តើមប្រតិបត្តិការ ហើយអតិថិជនមិនមានការចំណាយកំរៃសេវានៅពេលទទួលប្រាក់ទៀតឡើយ។

សេចក្តីជូនដំណឹងនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ភ្នំពេញ, ថ្ងៃទី ១០ ខែមករា ឆ្នាំ២០០៣

**អគ្គនាយក**

ហត្ថលេខានិងត្រា: **ឆាល់ ណៃអ៊ីម**

គំរូលេខ១១

ថ្ងៃទី ខែ ឆ្នាំ

....... ............Date.................

**បញ្ជាផ្ទេរប្រាក់**

Transfer Order

**សូមជំរាបជូន**

**នាយក / នាយិកា សាខាធនាគារជាតិនៃកម្ពុជា**

TO: Manager of the National Bank of Cambodia

**ខេត្ត-ក្រុង**

Branch.................................

- អង្គភាព/ ស្ថាប័ន/ គ្រឹះស្ថាន:
  Equity/ Institution

:.........................................................................................................

- អ្នកដែលទទួលសិទ្ធិ:
  Authorized Person:.....................................................................................................
- យោងលិខិតផ្ទេរសិទ្ធិលេខ ចុះថ្ងៃទី
  Reference the Proxy No...........................Date.......................................................
- ចំនួនប្រាក់:
  Amount .........................................................................................................
- អ្នកទទួលប្រាក់:
  Beneficiary Name............................................................................................
- លេខគណនី:
  Account Number.............................................................................................
- ធនាគារអ្នកទទួលប្រាក់ :
  Beneficiary Bank.............................................................................................
- អាសយដ្ឋាន
  Address of Beneficiary Bank...............................................................................
- បញ្ជាពិសេស : សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ
  ដែលបានបើកនៅធនាគារលោក/ លោកស្រី
  Special Instruction : please debit our account n....................................................
  opened with your bank.

**ហត្ថលេខា**

Signature

គំរូលេខ១២

ថ្ងៃទី ខែ ឆ្នាំ

...... ............Date.................

# បញ្ជាផ្ទេរប្រាក់

Transfer Order

**សូមជំរាបជូន**

**នាយក / នាយិកា សាខាធនាគារជាតិនៃកម្ពុជា**

TO: Manager of the National Bank of Cambodia

**ខេត្ត-ក្រុង**

Branch.................................

- អ្នកផ្ទេរប្រាក់ :
  Name of transferor ........................................................................................
- អាសយដ្ឋាន :
  Address.........................................................................................................
- អត្តសញ្ញាណប័ណ្ណ / លិខិតឆ្លងដែន :
  ID Card or Passport No..................................................................................
- ចំនួនប្រាក់:
  Amount..........................................................................................................
- អ្នកទទួលប្រាក់ :
  Beneficiary Name..........................................................................................
- លេខគណនី :
  Account Number............................................................................................
- ធនាគារអ្នកទទួលប្រាក់ :
  Beneficiary Bank............................................................................................
- បញ្ជាពិសេស : សូមចុះឥណពន្ធលើគណនីរបស់យើងខ្ញុំលេខ
  ដែលបានបើកនៅធនាគារលោក / លោកស្រី
  Special Instruction: please debit our account n......................................................
  opened with your bank

**ហត្ថលេខា**

Signature